ធ ៥-០៣-០១៦ សជណ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការផ្ទេរការទៅ-មក ខេត្ត-ក្រុង
# និងការកំណត់កំរៃសេវា

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជំរាបជូនដំណឹងដល់អតិថិជនដែលមានបើកគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា និងតាមសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងជ្រាបថា ធនាគារជាតិនៃកម្ពុជាផ្តល់សេវាផ្ទេរប្រាក់ទៅ-មកខេត្តក្រុង តាមរយៈនាយកដ្ឋានប្រតិបត្តិការ និងសាខាធនាគារជាតិ នៃ កម្ពុជាខេត្ត-ក្រុងចាប់ពីពេលជូនដំណឹងនេះតទៅ ។

## I **អតិថិជនដែលទទួលបាននូវការផ្តល់សេវា**

១- ផ្ទេរប្រាក់ពីធនាគារជាតិនៃកម្ពុជាទៅសាខាធនាគារជាតិខេត្ត-ក្រុង :

- ក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានបើកគណនីនៅនាយកដ្ឋាន ប្រតិបត្តិការ

២- ផ្ទេរប្រាក់ពីសាខាធនាគារខេត្ត-ក្រុងមកធនាគារជាតិនៃកម្ពុជា

- រតនាគារខេត្ត-ក្រុង
- មន្ទីរស្ថាប័នខេត្ត-ក្រុង កំពង់ផែ អគ្គិសនី រដ្ឋាករទឹក
- សាខាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- អង្គការក្រៅរដ្ឋាភិបាល អង្គការសង្គម
- អាជីវករប្តូរប្រាក់ និង លោហធាតុមានតម្លៃដែលមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា

## II **បែបបទផ្ទេរប្រាក់**

អតិថិជនត្រូវបំពេញនូវបញ្ជាផ្ទេរប្រាក់តាមគំរូលេខ ១១ ចំពោះអតិថិជនជានីតិបុគ្គល ឬ តាមគំរូលេខ ១២ ចំពោះអតិថិជនជាឯកត្តជន ដោយភ្ជាប់ជាមួយនូវមូលប្បទានប័ត្រដកប្រាក់ពីគណនីរបស់ខ្លួន ។

( សូមភ្ជាប់ជាមួយនេះនូវគំរូលេខ ១១ និងគំរូលេខ ១២ )

## III **កំរៃសេវា**

- កំរៃសេវាត្រូវគិតលើចំនួនប្រាក់ផ្ទេរ 0.១0% ( ជាប្រាក់រៀល ឬ ប្រាក់ដុល្លារអាមេរិក)

- កំរិតអប្បបរមា ១២.០០០រៀល ឬ ៣ ដុល្លារ ក្នុងប្រតិបត្តិការផ្ទេរប្រាក់១លើក ការផ្ទេរប្រាក់ដែលជាថវិការដ្ឋមិនគិតកំរៃសេវាទេ។

កំរៃសេវាត្រូវបានគិតយកពីអតិថិជននៅធនាគារផ្តើមប្រតិបត្តិការ ហើយអតិថិជនមិនមានការចំណាយកំរៃសេវានៅពេលទទួលប្រាក់ទៀតឡើយ ។

សេចក្តីជូនដំណឹងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៣

**អគ្គនាយក**

ហត្ថលេខា និងត្រា **តាល់ ណែអ៊ីម**

គំរូលេខ១១

ថ្ងៃទី ខែ ឆ្នាំ

....... ............Date.................

# **បញ្ជាផ្ទេរប្រាក់**

Transfer Order

**សូមជំរាបជូន**

**នាយក / នាយិកា សាខាធនាគារជាតិនៃកម្ពុជា**

TO : Manager of the National Bank of Cambodia

**ខេត្ត-ក្រុង**

Branch.................................

- អង្គភាព / ស្ថាប័ន / គ្រឹះស្ថាន :
  Entity/ Institution :........................................................................................
- អ្នកដែលទទួលសិទ្ធិ :
  Authorized Person :..........................................................................................
- យោងលិខិតផ្ទេរសិទ្ធិលេខ ចុះថ្ងៃទី
  Reference the Proxy No.................Date..........................................................
- ចំនួនប្រាក់ :
  Amount...............................................................................................
- អ្នកទទួលប្រាក់ :
  Beneficiary Name....................................................................................
- លេខគណនី :
  Account Number....................................................................................
- ធនាគារអ្នកទទួលប្រាក់ :
  Beneficiary Bank....................................................................................
- អាស័យដ្ឋាន
  Address of Beneficiary Bank.........................................................................
- **បញ្ជាពិសេស :** សូមចុះឥណពន្ធលើគណនីរបស់យើងខ្ញុំលេខ
  ដែលបានបើកនៅធនាគារលោក / លោកស្រី
  **Special Instruction :** please debit our accoun n...........................................
  opened with your bank.

**ហត្ថលេខា**

Signature

គំរូលេខ១២

ថ្ងៃទី ខែ ឆ្នាំ

....... ............Date.................

# **បញ្ជាផ្ទេរប្រាក់**

Transfer Order

**សូមជំរាបជូន**

**នាយក / នាយិកា សាខាធនាគារជាតិនៃកម្ពុជា**

TO : Manager of the National Bank of Cambodia

**ខេត្ត~ក្រុង**

Branch.................................

- អ្នកផ្ទេរប្រាក់ :
  Name of transferor...........................................................................................
- អាស័យដ្ឋាន
  Address...................................................................................................................
- អត្តសញ្ញាណប័ណ្ណ / លិខិតឆ្លងដែន
  ID Card or Passport No........................................................................................
- ចំនួនប្រាក់ :
  Amount....................................................................................................................
- អ្នកទទួលប្រាក់ :
  Beneficiary Name......................................................................................
- លេខគណនី :
  Account Number.........................................................................................
- ធនាគារអ្នកទទួលប្រាក់ :
  Beneficiary Bank........................................................................................
- **បញ្ជាពិសេស :** សូមចុះឥណពន្ធលើគណនីរបស់យើងខ្ញុំលេខ
  ដែលបានបើកនៅធនាគារលោក / លោកស្រី
  **Special Instruction :** please debit our accoun n..........................................
  opened with your bank.

**ហត្ថលេខា**

Signature